# កិច្ចព្រមព្រៀង

## រវាង

## រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង

## រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម

## ស្តីពី កិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរស្ត្រី និងកុមារ

## និង ជួយដល់ជនរងគ្រោះដោយសារការជួញដូរ

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលតទៅនេះកំណត់ ថា " រដ្ឋជាភាគី "

ដោយមានបំណងពង្រឹងបន្ថែមទៀតនូវចំណងមិត្តភាពរវាងប្រទេសទាំងពីរ និងបង្កើនកិច្ចសហប្រតិបត្តិការទ្វេភាគី ស្តីពីការបង្ក្រាបការជួញដូរមនុស្ស

ដោយទទួលស្គាល់ទៅវិញទៅមកថា ការជួញដូរស្ត្រី និងកុមារ គឺជាការរំលោភបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ ហើយជាការជាន់ឈ្លីយ៉ាងធ្ងន់ទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ

ដោយមានការព្រួយបារម្ភជាខ្លាំងថា ការជួញដូរស្ត្រី និងកុមារជះឥទ្ធិពលជាអវិជ្ជមានទៅលើការរីកចំរើនសរីរាង្គបុគ្គល គំនិតស្មារតី ទឹកចិត្ត សីលធម៌ និង ធ្វើអោយខូចប្រយោជន៍ជាមូលដ្ឋាន និង តម្លៃនៃសង្គម

ដោយយល់ឃើញថា ក្រុមនិងអង្គការឧក្រិដ្ឋកម្មឆ្លងប្រទេសមានការទាក់ទិនយ៉ាងសកម្មទៅនឹងការជួញដូរស្ត្រី និងកុមារ ហើយឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង និងមានលក្ខណៈឆ្លងប្រទេសបែបនេះ មិនគ្រាន់តែជះឥទ្ធិពលអាក្រក់ដល់ប្រទេសវៀតណាម និងប្រទេសកម្ពុជាប៉ុណ្ណោះទេ គឺប៉ុន្តែថែមទាំងជះឥទ្ធិពលអាក្រក់ដល់បណ្តាប្រទេសក្នុងតំបន់ និងសហគមន៍ពិភពលោកទាំងមូលផងដែរ

ដោយយោងតាម ពិធីសារនៃអង្គការសហប្រជាជាតិ ស្តីពីការបង្ការ ទប់ស្កាត់ ការបង្ក្រាប និងការផ្តន្ទាទោសអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ដែលបំពេញបន្ថែមទៅលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងនឹងឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង និងមានលក្ខណៈឆ្លងប្រទេស

ដោយជឿជាក់ថា ការបង្ក្រាបបទឧក្រិដ្ឋជួញដូរស្ត្រី និងកុមារ តាមរយៈកិច្ចសហប្រតិបត្តិការទៅវិញទៅមកក្នុងការអនុវត្តច្បាប់ និងក្នុងនីតិវិធីព្រហ្មទណ្ឌ គឺជាវិធានការដ៏មានប្រសិទ្ធិភាពក្នុងការធានានូវយុត្តិធម៌ប្រឆាំងនឹងការជួញដូរមនុស្ស

ដោយសន្យាថា រដ្ឋជាភាគីនឹងធ្វើកិច្ចសហការយ៉ាងស្មោះស្ម័គ្រក្នុងការលុបបំបាត់ការជួញដូរស្ត្រី និងកុមារ និងជួយដល់ជនរងគ្រោះពីការជួញដូរមនុស្ស

បានព្រមព្រៀងគ្នា ដូចតទៅ :

## ជំពូកទី I
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ក្នុងក្របខ័ណ្ឌនៃការអនុវត្តកិច្ចព្រមព្រៀងនេះ ន័យមួយចំនួនត្រូវបានបកស្រាយដូចតទៅ :

១- " ការជួញដូរស្ត្រី និងកុមារ " មានន័យថា ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់ជម្រកលាក់ខ្លួន ឬការទទួលមនុស្សដោយប្រើមធ្យោបាយគម្រាមកំហែងដោយការប្រើប្រាស់កម្លាំង ឬដោយការប្រើប្រាស់ទម្រង់ផ្សេងទៀតនៃការបង្ខិតបង្ខំ ដូចជាការចាប់ពង្រត់ ការឆបោក ការបំភ័ន្តបោកប្រាស់ ការរំលោភបំពានលើអំណាច ឬលើស្ថានភាពដែលងាយរងគ្រោះ ឬការឱ្យប្រគល់ ឬទទួលប្រាក់ ឬផលប្រយោជន៍ផ្សេងៗ ដើម្បីទទួលបានការយល់ព្រមពីជនណាម្នាក់ដែលគ្រប់គ្រងលើមនុស្សម្នាក់ទៀត ក្នុងគោលបំណងធ្វើការកេងប្រវ័ញ្ច ។

ការកេងប្រវ័ញ្ចរួមមាន : ការកេងប្រវ័ញ្ចលើពេស្យាកម្មអ្នកដទៃ ឬទម្រង់ផ្សេងៗទៀតនៃការកេងប្រវ័ញ្ចផ្លូវភេទ ការផ្តល់ការងារ ឬផ្តល់សេវាដោយចាប់បង្ខំ ទាសករដាច់ថ្លៃ ឬការអនុវត្តនានា ដែលមានលំនាំដូចជាទាសករដាច់ថ្លៃសេវគតិភាព ឬការកាត់យកចេញនូវសរីរាង្គណាមួយ ។

២- ការយល់ព្រមរបស់ជនរងគ្រោះណាម្នាក់នៃការជួញដូរស្ត្រី និងកុមារចំពោះការកេងប្រវ័ញ្ចដែលមានគោលបំណងដូចបានចែងនៅក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះ មិនទាក់ទងទៅនឹងមធ្យោបាយណាមួយដែលមានចែង នៅក្នុងវាក្យខ័ណ្ឌទី ១ ដែលត្រូវបានប្រើនោះឡើយ ។

៣- ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់ជម្រកលាក់បំពួន ឬការទទួលកុមារណាម្នាក់ ក្នុងគោលបំណងធ្វើការកេងប្រវ័ញ្ចនឹងត្រូវចាត់ទុកជា " ការជួញដូរ " ទោះបីជាបញ្ហានេះមិនទាក់ទងទៅនឹងមធ្យោបាយណាមួយដែលមានចែងនៅក្នុងវាក្យខ័ណ្ឌ (ក) នៃមាត្រានេះក៏ដោយ ។

៤- " កុមារ " មានន័យថា ជនណាម្នាក់ដែលមានអាយុក្រោម ១៨ ឆ្នាំ ។

មាត្រា ២.-

ភាគីទាំងពីរទទួលស្គាល់ថា គំរូទាំងឡាយនៃបំណងក្នុងការជួញដូរស្ត្រី និងកុមារ នៅក្នុងកិច្ចព្រមព្រៀងនេះមានយ៉ាងតិចបំផុត ដូចតទៅ :

១- ពេស្យាចារ

២- ការងារក្នុងគេហដ្ឋាន ដូចជា ការងារផ្ទះដែលគេបង្ខំ ឬ កេងប្រវ័ញ្ច

៣- ពលកម្មកុមារ

៤- ការងាររំលោះបំណុល

៥- អាពាហ៍ពិពាហ៍ ក្នុងឆន្ទៈទុច្ចរិត

៦- សុំកូនក្លែងក្លាយ ក្នុងឆន្ទៈទុច្ចរិត

៧- ការកំសាន្ត និង ទេសចរណ៍ផ្លូវភេទ

៨- រូបភាព និង សម្ភារៈអាសអាភាស

៩- ការសុំទាន និង ពលកម្មដែលមានលក្ខណៈធ្ងន់ធ្ងរ គ្រោះថ្នាក់ និងកេងប្រវ័ញ្ចនី

១០- ការប្រើប្រាស់ក្នុងសកម្មភាពទាក់ទិននឹងបទល្មើសព្រហ្មទណ្ឌ

១១- ការប្រើប្រាស់គ្រឿងញៀនជាមធ្យោបាយដើម្បីធ្វើអោយស្ត្រី និង កុមារក្លាយជាទាសករ ។

## ផ្នែកទី II
## វិធានការទប់ស្កាត់

មាត្រា ៣.-

រដ្ឋជាភាគីត្រូវស្នើអោយមានការកែទម្រង់ច្បាប់តាមការចាំបាច់ និងចាត់វិធានការសមស្របផ្សេងៗទៀត ដើម្បីធានាក្របខ័ណ្ឌច្បាប់នៅក្នុងយុត្តាធិការរៀងៗខ្លួន ដោយអនុលោមទៅតាមសេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្ស អនុសញ្ញាស្ដីពីសិទ្ធិកុមារ អនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើង ប្រឆាំងនារីភេទ និងឧបករណ៍សិទ្ធិមនុស្សផ្សេងៗទៀត ព្រមទាំងអនុសញ្ញាដទៃទៀតដែលពាក់ព័ន្ធនឹងការបង្ក្រាបការជួញដូរមនុស្ស ដែលភាគីទាំងពីរបានផ្ដល់សច្ចាប័ន ។

### មាត្រា ៤.-

ភាគីទាំងពីរត្រូវធ្វើការប្រឹងប្រែង ដើម្បីទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ តាមរយៈវិធានការទប់ស្កាត់ដូចតទៅ :

១. អនុវត្តកម្មវិធីអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈសំរាប់ស្ត្រី និងកុមារ ដើម្បីបង្កើនឱកាសសំរាប់ការអប់រំ និងការងារ និងកាត់បន្ថយភាពងាយរងគ្រោះដោយសារការជួញដូរ

២. បង្កើនការផ្តល់សេវាកម្មសង្គមដូចជា ជួយរកការងារអោយធ្វើដើម្បីអោយមានចំណូល និងផ្តល់ការថែទាំសុខភាពដល់ស្ត្រី និងកុមារដែលងាយរងគ្រោះដោយសារការជួញដូរ

៣. បង្កើនការយល់ដឹងដល់សាធារណជន អំពីបញ្ហាជួញដូរស្ត្រី និងកុមារ

៤. ផ្សព្វផ្សាយពត៌មានដល់សាធារណជនស្តីពីគ្រោះថ្នាក់ និងផលវិបាកដែលទាក់ទិននឹងការជួញដូរស្ត្រី និងកុមារ និងស្តីពីការធ្វើអាជីវកម្មដែលកេងប្រវ័ញ្ចលើស្ត្រី និងកុមារ ។

## ផ្នែកទី III : កិច្ចការពារជនរងគ្រោះដោយសារគេជួញដូរ

### មាត្រា ៥.-

ជនដែលត្រូវគេជួញដូរនឹងត្រូវបានចាត់ទុកជាជនរងគ្រោះ ហើយមិនមែនជាអ្នករំលោភបំពាន ឬជាជនល្មើសច្បាប់អន្តោប្រវេសន៍ទេ ដោយថា :

១. ស្ត្រី និងកុមារដែលត្រូវគេជួញដូរ មិនត្រូវបានចោទប្រកាន់ពីបទអន្តោប្រវេសន៍ខុសច្បាប់ ឬពេស្យាចារឡើយ

២. ស្ត្រី និងកុមារដែលត្រូវគេជួញដូរ មិនត្រូវបានឃុំខ្លួននៅក្នុងមណ្ឌលឃុំឃាំងអន្តោប្រវេសន៍ក្នុងពេលរង់ចាំដំណើរការធ្វើមាតុភូមិនិវត្តន៍ជាផ្លូវការមកកាន់ប្រទេសខ្លួនវិញនោះទេ ។ ពួកគេនឹងស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋជាភាគី ។ ជម្រក និងការការពារ ត្រូវបាន ផ្តល់ដល់ជនរងគ្រោះទៅតាមច្បាប់របស់រដ្ឋនីមួយៗ

៣. អាជ្ញាធរពាក់ព័ន្ធត្រូវធានាសន្តិសុខដល់ជនដែលត្រូវគេជួញដូរ

៤. ជនរងគ្រោះត្រូវទទួលបាននូវការថែទាំចំពោះខ្លួនដោយមនុស្សធម៌ នៅក្នុងកិច្ចដំណើរការទាំងមូលនៃកិច្ចការពារ ការធ្វើមាតុភូមិនិវត្តន៍ និងនៅក្នុងនីតិវិធីតុលាការ ។

**មាត្រា ៦.-**

រដ្ឋជាភាគីត្រូវចាត់វិធានការសមស្របនានា ដើម្បីធានាអោយប្រាកដនូវដំណោះស្រាយតាមផ្លូវច្បាប់ចំពោះជនរងគ្រោះដោយសារការជួញដូរដូចតទៅ :

១. ជនរងគ្រោះអាចប្តឹងទាមទារមកវិញនូវទ្រព្យសម្បត្តិ និងសម្ភារៈជាប់ខ្លួនដែលគ្មានវិវាទ ហើយដែលត្រូវបានយកដោយអាជ្ញាធរមានសមត្ថកិច្ចនៅក្នុងដំណើរការនៃការឃាត់ខ្លួន

២. ជនល្មើសក្នុងករណីជួញដូរ ត្រូវប្រគល់អោយទៅជនរងគ្រោះវិញនូវទ្រព្យសម្បត្តិដែលខ្លួនបានយកពីការជួញដូរ ឬការកេងប្រវ័ញ្ចលើស្ត្រី និងកុមារ

៣. ជនរងគ្រោះអាចប្តឹងទារសំណងពីជនល្មើសនូវការខូចខាតទាំងឡាយ ដែលបង្កឡើងដោយការជួញដូរស្ត្រី និងកុមារ

៤. ជនរងគ្រោះអាចទាមទារផលកម្រៃពលកម្មដែលមិនទាន់បានទទួលពីជនល្មើស ដែលជនរងគ្រោះត្រូវបានជនល្មើសបង្ខំអោយធ្វើសកម្មភាព

៥. ជនរងគ្រោះត្រូវទទួលបាននូវនីតិវិធីសមស្របតាមច្បាប់ សំរាប់ការទាមទាររកភាពយុត្តិធម៌ក្នុងរឿងក្តីព្រហ្មទណ្ឌ និងការជួសជុលការខូចខាត និងដំណោះស្រាយផ្សេងៗទៀតតាមផ្លូវតុលាការ ។

## ផ្នែកទី IV

## កិច្ចសហការក្នុងការបង្ក្រាបការជួញដូរស្ត្រី និង កុមារ

**មាត្រា ៧.-**

អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទាំងពីរ ជាពិសេសនៅតាមច្រកព្រំដែនត្រូវសហការគ្នាដោយជិតស្និទ្ធក្នុងការស្វែងរកអោយឃើញនូវការជួញដូរស្ត្រី និងកុមារក្នុងស្រុក និងឆ្លងដែន ធ្វើអោយរឹតតែខ្លាំងក្លាឡើងទៀតនូវការស៊ើបអង្កេត និងផ្តន្ទាទោសជនល្មើស ព្រមទាំងបណ្តាញឧក្រិដ្ឋជន ដែលទាក់ទងទៅនឹងការជួញដូរស្ត្រី និងកុមារ ។

**មាត្រា ៨.-**

រដ្ឋជាភាគីត្រូវខិតខំទទួលរៀបចំកម្មវិធីបណ្តុះបណ្តាលជាឯកតោភាគី និងជាទ្វេភាគីស្តីពីការអនុវត្តវិធានគតិយុត្ត និងចំណេះដឹងស្តីពីការស៊ើបអង្កេត និងកិច្ចការពារដែលទាក់ទងនឹងករណីនៃការជួញដូរដល់មន្ត្រីទទួល

បន្តកអនុវត្តច្បាប់ ដោយយោងតាមអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើង ប្រឆាំងនារីភេទ អនុសញ្ញាស្តីពីសិទ្ធិកុមារ បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិផ្សេងៗទៀត ព្រមទាំងច្បាប់ក្នុងស្រុកដែលពាក់ព័ន្ធ ។

**មាត្រា ៩.-**

១-អាជ្ញាធរពាក់ព័ន្ធនៃប្រទេសទាំងពីរ ត្រូវធ្វើសហប្រតិបត្តិការលើការផ្លាស់ប្តូរព័ត៌មានទាក់ទងនឹងករណីនៃការជួញដូរ មានជាអាទិ ច្រកជួញដូរ ទីកន្លែងជួញដូរ អត្តសញ្ញាណនៃអ្នកជួញដូរ បណ្តាញជួញដូរ វិធីសាស្ត្រជួញដូរ និងទិន្នន័យស្តីពីអ្នកដែលត្រូវបានគេជួញដូរ និងព័ត៌មានពាក់ព័ន្ធផ្សេងៗទៀត ។

២- ពត៌មាន និង ភស្តុតាងដែលប្រមូលបានដូចមានចែងក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះ ត្រូវប្រគល់អោយបានទាន់ពេលវេលាដល់អាជ្ញាធរមានសមត្ថកិច្ចនៃភាគីនីមួយៗ ដើម្បីចាត់វិធានការតាមផ្លូវច្បាប់ដែលមានជាអាទិ ការស្វែងរកជនល្មើស ការស៊ើបអង្កេតករណី ការចោទប្រកាន់ជនល្មើស និងដំណើរការ ក្នុងនីតិវិធីតុលាការផ្សេងៗទៀត ។

៣- នគរបាល និងអាជ្ញាធរពាក់ព័ន្ធផ្សេងៗទៀតនៃរដ្ឋជាភាគី ត្រូវអនុវត្តនូវកម្មវិធីការពារ ដើម្បីធានាសុវត្ថិភាពជនរងគ្រោះ និងសាក្សីពីការសងសឹក ការគម្រាមកំហែង នៅក្នុងពេលដំណើរការរឿងក្តី និងក្រោយពីដំណើរការរឿងក្តីតាមនីតិវិធីតុលាការ បើចាំបាច់ ។

៤- ការផ្លាស់ប្តូរពត៌មាន និងភស្តុតាងត្រូវធានាការសម្ងាត់ ហើយពត៌មាន និងភស្តុតាងទាំងនេះ មិនត្រូវបញ្ជូនទៅអោយភាគីទី ៣ ដោយគ្មានការយល់ព្រមជាលាយល័ក្ខអក្សររបស់ភាគីដែលផ្តល់ឡើយ ។

**មាត្រា ១០.-**

រដ្ឋជាភាគីត្រូវអនុញ្ញាតអោយស្ថាប័នដែលពាក់ព័ន្ធ ដើម្បីចងក្រង ចរចា មកចូលរួមក្នុងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងជំនួយយុត្តិធម៌ទៅវិញទៅមកក្នុងរឿងក្តីព្រហ្មទណ្ឌ និងរដ្ឋប្បវេណី ក្នុងគោលបំណងបង្កើតមូលដ្ឋានរឹងមាំសំរាប់កិច្ចសហការទ្វេភាគីក្នុងការស្រាវជ្រាវ ការស៊ើបអង្កេត ការចោទប្រកាន់ និងការជំនុំជំរះ ចំពោះបទល្មើសទាំងឡាយដែលពាក់ព័ន្ធប្រទេសទាំងពីរ រួមទាំងបទល្មើសនៃការជួញដូរស្ត្រី និងកុមារផងដែរ ។

## ផ្នែកទី V

## ការធ្វើមាតុភូមិនិវត្តន៍ និង សមាហរណកម្ម

**មាត្រា ១១.-**

១- ភាគីទាំងពីរត្រូវប្រើប្រាស់ផ្លូវការទូត ដើម្បីរៀបចំការធ្វើមាតុភូមិនិវត្តន៍ជនដែលត្រូវបានគេជួញដូរ ។

២- ការធ្វើមាតុភូមិនិវត្តន៍ជនដែលត្រូវបានគេជួញដូរ ត្រូវរៀបចំឡើងយ៉ាងឆាប់ មានសុវត្ថិភាព និង គោរពនូវសេចក្តីថ្លៃថ្នូររបស់ពួកគេ និងប្រព្រឹត្តទៅក្នុងផលប្រយោជន៍ដ៏ល្អបំផុត ទៅតាមលក្ខណ្ឌ និងនយោបាយ របស់រដ្ឋជាភាគីនីមួយៗ ស្របទៅតាមច្បាប់អន្តរជាតិ និងការអនុវត្តជាក់ស្តែង ។

៣- ក្នុងពេលធ្វើមាតុភូមិនិវត្តន៍ ជនរងគ្រោះត្រូវបានជួយលើផ្នែកមនុស្សធម៌ពីរដ្ឋជាភាគីទាំងពីរ ។

**មាត្រា ១២.-**

១- ក្នុងករណីចាំបាច់ ភាគីនីមួយៗត្រូវបង្កើតក្រុមការងារដែលមានសមាសភាពពីតំណាងអាជ្ញាធរមាន សមត្ថកិច្ចរបស់ខ្លួន ដើម្បីរៀបចំដំណើរការធ្វើមាតុភូមិនិវត្តន៍សំរាប់ជនរងគ្រោះដោយសារការជួញដូរ ។

២- ក្រុមការងារនៃរដ្ឋជាភាគីនីមួយៗ មានការទទួលខុសត្រូវ ដូចតទៅ :

- រៀបចំការធ្វើមាតុភូមិនិវត្តន៍ សំរាប់ជនដែលត្រូវបានគេជួញដូរ
- អនុវត្តដំណើរការ ការធ្វើមាតុភូមិនិវត្តន៍ជនត្រូវបានគេជួញដូរ នៅពេលដែលបានរៀបចំរួច
- ធានាការពារសន្តិសុខដល់ជនដែលត្រូវបានគេជួញដូរនៅក្នុងដំណើរការធ្វើមាតុភូមិនិវត្តន៍

៣-ក្រុមការងារនៃរដ្ឋជាភាគីទាំងពីរ ត្រូវបានកោះអញ្ជើញចូលរួមកិច្ចប្រជុំនៅពេលដែលមានសំណូមពរ ។ ពេលវេលា និងទីកន្លែងប្រជុំ ត្រូវបានការយល់ព្រមពីរដ្ឋជាភាគីទាំងពីរ ។

**មាត្រា ១៣.-**

១- រដ្ឋជាភាគី ត្រូវខិតខំឱ្យអស់លទ្ធភាព ដើម្បីសំរេចបាននូវការធ្វើសមាហរណកម្មប្រកបដោយសុវត្ថិ ភាព និងមានប្រសិទ្ធិភាពចំពោះជនរងគ្រោះដោយសារការជួញដូរ ទៅក្នុងក្រុមគ្រួសាររបស់គេ និងសហគមន៍ ដើម្បីឱ្យគេទទួលបាននូវសេចក្តីថ្លៃថ្នូរ សេរីភាព និងការទុកចិត្តលើខ្លួនឯង ។

២- ក្នុងគោលបំណងនេះ រដ្ឋជាភាគីត្រូវចាត់វិធានការសមស្របនានា ដើម្បីសំរេចបាននូវគោលដៅ ដូចតទៅ:

- ជំនួយលើផ្នែកសង្គមកិច្ច សុខាភិបាល ចិត្តសាស្ត្រ និងការគាំទ្រចាំបាច់ផ្សេងៗទៀតត្រូវតែ ផ្តល់អោយជនរងគ្រោះដោយសារការជួញដូរ និងគ្រួសាររបស់គេ ជាពិសេសចំពោះអ្នកដែលឆ្លងជម្ងឺកាមរោគ ក្នុងនោះរួមទាំងជម្ងឺ ឬមេរោគអេដស៍ផង
- ស្ត្រី និងកុមាររងគ្រោះដោយសារការជួញដូរ ពុំត្រូវទទួលការរើសអើងពីសង្គម ឬរងការ ធ្វើអោយអាម៉ាស់ដោយសារស្នាកស្នាមអាស្រូវនោះឡើយ

-កុមាររងគ្រោះដែលមានវ័យត្រូវចូលសាលា ត្រូវបានធានានូវឱកាសទទួលការអប់រំដ៏សមស្រប ។

# ផ្នែកទី VI
# ស្ថាប័នអនុវត្ត

**មាត្រា ១៤.-**

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចាត់តាំងក្រសួងកិច្ចការនារីកម្ពុជា ហើយរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចាត់តាំងក្រសួងសន្តិសុខសាធារណៈវៀតណាម ជាស្ថាប័នអនុវត្តកិច្ចព្រមព្រៀងនេះ ដោយមានក្រុមការងារដែលមានតំណាងមកពីក្រសួងនានាជាជំនួយការ ។

**មាត្រា ១៥.-**

ស្ថាប័នអនុវត្ត មានការទទួលខុសត្រូវដូចខាងក្រោម :

១- បង្កើតយុទ្ធសាស្ត្រ គោលការណ៍រាប់ដឹកនាំ របនាសម្ព័ន្ធចាត់តាំង និងផ្នែកចាំបាច់ផ្សេងៗទៀត ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ រាយការណ៍ជូនគណៈកម្មការរួមនៃកិច្ចសហប្រតិបត្តិការទ្វេភាគី រវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម ក្នុងកិច្ចប្រជុំប្រចាំឆ្នាំ

២- លើកឡើងនូវអនុសាសន៍សំដៅអោយមានការរីកចំរើនតទៅទៀត នូវកិច្ចសហប្រតិបត្តិការជួយគ្នាទៅវិញទៅមក ក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរស្ត្រី និងកុមារ

៣- ពិនិត្យឡើងវិញ និងវាយតំលៃលើការអនុវត្តន៍កិច្ចព្រមព្រៀងនេះរៀងរាល់ ២ ឆ្នាំម្តង ដើម្បីយកជាបទពិសោធន៍សំរាប់ឆ្នាំបន្តបន្ទាប់ទៀត

៤- ដោះស្រាយជម្លោះដែលទាក់ទងដល់ការបកស្រាយ ឬការអនុវត្តកិច្ចព្រមព្រៀងនេះតាមរយៈការចរចា។ ក្នុងករណីមិនអាចព្រមព្រៀងគ្នាតាមរយៈការចរចាទេនោះ ជម្លោះទាំងនោះត្រូវរាយការណ៍ជូនរដ្ឋាភិបាលនៃភាគីទាំងពីរដើម្បីដោះស្រាយ

៥- សម្រេចលើការបង្កើត ចាត់ចែង និងដឹកនាំប្រតិបត្តិការនៃក្រុមការងារដូចមានចែងក្នុងប្រការ ១២ នៃកិច្ចព្រមព្រៀង ។

## ផ្នែកទី VII : អវសានប្បញ្ញត្តិ

**មាត្រា ១៦.-**

១- កិច្ចព្រមព្រៀងនេះ អាចធ្វើវិសោធនកម្ម ឬបន្ថែមទៀតបាន ដោយឈរលើមូលដ្ឋាននៃការយល់ព្រមជាលាយលក្ខណ៍អក្សររបស់ភាគីទាំងពីរ ។ មាត្រា និងប្រការទាំងឡាយដែលបានឯកភាពដោយភាគីទាំងពីរសំរាប់ធ្វើវិសោធនកម្ម ឬបន្ថែម ត្រូវចាត់ទុកជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ ហើយមានសុពលភាពដូចគ្នានឹងកិច្ចព្រមព្រៀងនេះ ។

២- កិច្ចព្រមព្រៀងនេះ ត្រូវមានសុពលភាពនៅពេលដែលបានទទួលនូវសេចក្តីជូនដំណឹងជាលាយល័ក្ខអក្សរបញ្ជាក់ថា ភាគីទាំងពីរបានបញ្ចប់នូវនិតិវិធីផ្ទៃក្នុងខាងផ្លូវច្បាប់ សំរាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ។ កិច្ចព្រមព្រៀងនេះមានសុពលភាពរយៈ ពេល ៥ ឆ្នាំ និងត្រូវបានពន្យាពេលជាស្វ័យ ប្រវត្តិសំរាប់រយៈពេល ៥ ឆ្នាំបន្ទាប់ លើកលែងតែភាគីមួយបានជូនដំណឹងទៅភាគីម្ខាងទៀតតាមផ្លូវការទូត ក្នុងបំណងបញ្ចប់នូវសុពលភាពនៃកិច្ចព្រមព្រៀងយ៉ាងតិចរយៈពេល៣ ខែ មុនថ្ងៃដែលកិច្ចព្រមព្រៀងត្រូវបានបញ្ចប់ ។

៣- ការបញ្ចប់កិច្ចព្រមព្រៀងនេះ មិនត្រូវធ្វើអោយប៉ះពាល់ដល់នីតិវិធី ដែលផ្តើមអនុវត្តមុនការបញ្ចប់កិច្ចព្រមព្រៀងនេះឡើយ ។

៤- កិច្ចព្រមព្រៀងនេះ ធ្វើនៅហាណូយ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៥ ជាពីរច្បាប់ដើម ក្នុងមួយច្បាប់មានភាសា ខ្មែរ វៀតណាម និងអង់គ្លេស ហើយភាសាទាំងបីមានតម្លៃស្មើគ្នាខាងផ្លូវច្បាប់ ។ ក្នុងករណីមានការបកស្រាយមិន ស្របគ្នា អត្ថបទជាភាសាអង់គ្លេសត្រូវយកជាភាសាគោល ។

**តាងនាមរាជរដ្ឋាភិបាលកម្ពុជា**

**ទេជបណ្ឌិត អ៊ឹង កន្ថាផាវី**
**រដ្ឋមន្ត្រីក្រសួងកិច្ចការនារី**

**តាងនាមរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម**

**ឧត្តមសេនីយ៍ ឡេ ហុងអាញ់**
**រដ្ឋមន្ត្រីក្រសួងសន្តិសុខសាធារណៈ**